# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :.៧៦....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រង សកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦១ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាសភាពអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ :

អនុក្រឹត្យនេះកំណត់ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន និង កំណត់នូវតួនាទី និង ភារកិច្ចអគ្គលេខាធិការដ្ឋាន និង នាយកដ្ឋាននានាដែលនៅចំណុះ ។ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន អាចហៅថា "អាជ្ញាធរសកម្មភាពមីនកម្ពុជា" ឬ "អាជ្ញាធរមីន" ឬ ហៅជាអក្សរកាត់ភាសាអង់គ្លេសថា "ស៊ី.អ៊ឹម.អេ.អេ" (CMAA) នៅក្នុងអនុក្រឹត្យនេះហៅថា "អាជ្ញាធរ" ។

## ជំពូកទី ២

## និយមន័យ

មាត្រា ២ :

២.១. _ប័ណ្ណទទួលស្គាល់_ : គឺជានីតិវិធីដែលអង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់ ត្រូវបានការទទួលស្គាល់ជាផ្លូវការថាមានសមត្ថភាពក្នុងការរៀបចំផែនការ គ្រប់គ្រង និងធ្វើប្រតិបត្តិការសកម្មភាពមីន ប្រកបដោយសុវត្ថិភាព សុក្រឹត្យភាព និង ប្រសិទ្ធិភាពខ្ពស់ ។

២.២. _ម្ចាស់ជំនួយ_ : សំដៅលើអង្គការ ក្រុមហ៊ុន សមាគម ស្ថាបនិក ក្នុងប្រទេស និង អន្តរជាតិ ព្រមទាំងបណ្តាប្រទេសដែលបានសន្យាផ្តល់ជំនួយបច្ចេកទេស ឬថវិកា ដោយផ្ទាល់ ឬដោយប្រយោលដល់សកម្មភាពទាំឡាយ ទាំងការកំចាត់មីន និង គំរោងអភិវឌ្ឍន៍ផ្សេងៗ មានហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ ការថែទាំងសុខភាព ។ល។ ក្នុងប្រទេសកម្ពុជា ។

២.៣. _អចលនទ្រព្យ_ : សំដៅលើទ្រព្យសម្បត្តិសំរាប់ប្រើប្រាស់បានរយៈពេលយូរ មានជាអាទិ៍ អាគារ សំភារៈបរិក្ខារ ដីធ្លី ដែលមានវត្តមានជារូបីយ ហើយដែលត្រូវប្រើប្រាស់ក្នុងប្រតិបត្តិការដោយអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ។

២.៤. _អាជ្ញាប័ណ្ណ_ : គឺជាវិញ្ញាបនប័ត្រដែលចេញឱ្យដោយ "អាជ្ញាធរ" ចំពោះអង្គការប្រតិបត្តិករទាំងឡាយដែលមានសមត្ថភាពអាចបំរើសេវាកម្មលើកិច្ចប្រតិបត្តិការ ដូចជាកម្មវិធីយល់ដឹងពីមីន កម្ម

វិធីផ្ទៀងផ្ទាត់ស្រាវជ្រាវចំការមីន កម្មវិធីបោសសំអាតមីន កម្មវិធីហ្វឹកហ្វឺន កម្មវិធីសង្គ្រោះជនពិការដោយសារមីន កម្មវិធីអភិវឌ្ឍន៍បច្ចេកទេសជាដើម ។

២.៥. *អង្គការប្រតិបត្តិករជាតិ និងអន្តរជាតិ*: សំដៅលើអង្គការជាតិ និង អន្តរជាតិ និង បុគ្គលដែលពាក់ព័ន្ធនឹង "សកម្មភាពកំចាត់មីន" ដោយរួមទាំងស្ថាប័នរបស់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការសប្បុរសធម៌នានា ក្រុមហ៊ុនពាណិជ្ជកម្ម ក្រុមហ៊ុនឯកជន និង បុគ្គល ។

២.៦. *សកម្មភាពកំចាត់មីន* ឬ *សកម្មភាពមីន* ( មានន័យដូចគ្នា ): សំដៅលើសកម្មភាពទាំងឡាយដែលនាំទៅដល់ការកាត់បន្ថយនូវឥទ្ធិពលមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលប៉ះពាល់ដល់សេដ្ឋកិច្ច និង បរិយាកាសសង្គម ។ សកម្មភាពទាំងនោះ រួមមាន :

២.៦.១. កម្មវិធីយល់ដឹងអំពីមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ ការអប់រំ និង សកម្មភាពប្រហាក់ប្រហែល

២.៦.២. កម្មវិធីផ្ទៀងផ្ទាត់ស្រាវជ្រាវចំការមីន រួមមានកំរិត ១ កំរិត ២ និង កំរិត ៣ ការស្រាវជ្រាវសកម្មភាពមីន ក៏ដូចជាការអនុវត្តនីតិក្នុងការប្រមូល និងស្រាវជ្រាវទិន្នន័យដែលទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពមីន

២.៦.៣. ការកំណត់ទីកន្លែង ការដាក់ផ្លាកសញ្ញា ការយកចេញ ការដឹកជញ្ជូន ការរក្សាទុក ការធ្វើឱ្យអស់អនុភាព និង ការកំទេចចោលនូវមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ ។ សកម្មភាព ក៏មានរាប់បញ្ចូលផងដែរនូវគ្រឿងផ្ទុះប្រភេទដទៃៗទៀត ដែលបង្កការគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ ប៉ុន្តែមិនរាប់បញ្ចូលគ្រឿងរំសេវដែលមិនផ្ទុះ និង ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អាជ្ញាធរពាក់ព័ន្ធ

២.៦.៤. ការទទួលយក ការដឹកជញ្ជូន ការរក្សាទុក ការបែងចែក និង ការប្រើប្រាស់គ្រឿងផ្ទុះសំរាប់កំទេចមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ

២.៦.៥. កម្មវិធីហ្វឹកហ្វឺនបច្ចេកទេសទាក់ទងនឹងសកម្មភាពខាងលើ

២.៦.៦. កម្មវិធីសង្គ្រោះជនពិការដោយសារមីន

២.៦.៧. កម្មវិធីអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ ទាក់ទងទៅនឹងសកម្មភាពខាងលើ ។

២.៧. *យុទ្ធភណ្ឌមិនទាន់ផ្ទុះ* : សំដៅលើគ្រឿងផ្ទុះដែលត្រូវបានបំពាក់ឱ្យដំណើរការ ឬ ជាការដំឡើងសំរាប់ប្រើប្រាស់ ឬ បានប្រើប្រាស់ ។ វាអាចត្រូវបានបាញ់ ទំលាក់ ផ្លោង ឬ ក៏បាញ់ឱ្យខ្ទាតអំបែង

ហើយដែលនៅតែមិនផ្ទុះ ដោយហេតុថាការមិនដំណើរការស្រួល ឬ ក៏ការផលិតមិនបានល្អ ឬ ដោយហេតុផលផ្សេងៗ ។

២.៨. *សង្គ្រោះជនពិការដោយសារមីន* : សំដៅលើការសង្គ្រោះជនរងគ្រោះដែលបណ្តាលមកពីឧប្បទ្ទវហេតុផ្ទុះមីន និង យុទ្ធភណ្ឌគ្រប់ប្រភេទ ។ កិច្ចសង្គ្រោះនេះ ត្រូវលាតសន្ធឹងចាប់ពីការព្យាបាលតូចតាច រហូតដល់ការស្តារនាឡើងវិញនូវកាយសម្បទា និង ការឧបត្ថម្ភដល់ក្រុមគ្រួសារទាំងមូល ដើម្បីលើកកំពស់ផ្នែកសេដ្ឋកិច្ចសង្គម ។

## ជំពូកទី ៣

## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ៣ :

"អាជ្ញាធរ" មានបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចប្រតិបត្តិការសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅជំរុញចលនាបោសសំអាតមីន ការប្រើប្រាស់ជំនួយ និង ការបែងចែកដីធ្លីដែលបោសសំអាតមីនរួចហើយ អោយមានសុវត្ថិភាព ប្រសិទ្ធភាព និង តម្លាភាព ព្រមទាំងសំរបសំរួលកិច្ចប្រតិបត្តិការរវាងបណ្តាប្រតិបត្តិករទាំងអស់ ។

មាត្រា ៤ :

"អាជ្ញាធរ" មានភារកិច្ចដូចតទៅ :

៤.១. រៀបចំស្តង់ដា នីតិវិធី គោលការណ៍បច្ចេកទេស ថវិកា និង បទប្បញ្ញត្តិផ្សេងៗទាក់ទងទៅនឹងការធ្វើផែនការសកម្មភាពមីន និងការគ្រប់គ្រងពត៌មានបច្ចេកទេស

៤.២. រៀបចំផែនការជាតិសកម្មភាពមីន (និងរបាយការណ៍ពាក់ព័ន្ធ និងបន្តបន្ទាប់តាមពេល) រួមមាន :

៤.២.១. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ នៃសកម្មភាពមីន និង សកម្មភាពទ្រទ្រង់ផ្សេងៗ

៤.២.២. ពិនិត្យ និងជ្រើសរើសគំរោងស្នើ (ដោយផ្អែកលើផែនការសកម្មភាព) ដែលទាក់ទងទៅនឹងបញ្ហាមីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលភាគីពាក់ព័ន្ធនានាដាក់ជូនមកដើម្បីផ្ញើទៅម្ចាស់ជំនួយ

៤.២.៣. រៀបចំយុទ្ធសាស្ត្រផ្សេងៗ និងឯកសារដទៃទៀតដែលទាក់ទងទៅនឹងសកម្មភាពជាតិក្នុងការគ្រប់គ្រងលើវិស័យសកម្មភាពមីន

៤.៣. សំរបសំរួលរាល់ការងារសកម្មភាពមីន

៤.៤. តាមដាន និង ត្រួតពិនិត្យការងារសកម្មភាពមីន ដើម្បីឱ្យអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ទាំងអស់ អនុវត្តស្របតាមនយោបាយយុទ្ធសាស្ត្រ និង ផែនការរបស់រាជរដ្ឋាភិបាល

៤.៥. គៀងគរប្រភពធនធាន ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ទាំងក្នុង និង ក្រៅប្រទេស សំរាប់ដំណើរការសកម្មភាពមីន

៤.៦. បញ្ហាអោយកំទេចចោល :

៤.៦.១. គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

៤.៦.២. គ្រាប់មីនគ្រប់ប្រភេទប្រឆាំងរថក្រោះ និង ប្រឆាំងយានគ្រប់ប្រភេទ និង គ្រឿងផ្ទុះគ្រប់ប្រភេទ ដែលទុកចោលមិននៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច

៤.៦.៣. យុទ្ធភណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ

៤.៧. ផ្តល់ កែលំអ ដកហូតប័ណ្ណទទួលស្គាល់ និង អាជ្ញាប័ណ្ណពីអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិនានា ដែលធ្វើសកម្មភាពបោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា

៤.៨. គ្រប់គ្រងទិន្នន័យ និង ប្រព័ន្ធពត៌មាននានាដែលពាក់ព័ន្ធ ឬតំរូវការដែលទាមទារដោយ "អាជ្ញាធរ" ក្នុងការបំពេញមុខងាររបស់ខ្លួន

៤.៩. សំរបសំរួលជាមួយម្ចាស់ជំនួយ ភ្នាក់ងារអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ស្ថាប័នរដ្ឋនានា និងអាជ្ញាធរពាក់ព័ន្ធ ភ្នាក់ងារឯកជន ដើម្បីធានាឱ្យមានភាពរីកចំរើនជឿនលឿនដល់គំរោងការណ៍ក្នុងប្រទេសកម្ពុជា ហើយដែលត្រូវបាន និង កំពុងអនុវត្តក្នុងបរិយាកាសប្រកបដោយសុវត្ថិភាពកំរិតខ្ពស់.

៤.១០.សំរបសំរួលជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នរដ្ឋពាក់ព័ន្ធផ្សេងៗ ដើម្បីរៀបចំ និង ត្រួតពិនិត្យគោលនយោបាយ និង គោលការណ៍នានា ស្តីពីការប្រើប្រាស់ដីធ្លីដែលត្រូវបានបោសសំអាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះរួចហើយ

៤.១១.គ្រប់គ្រងការអនុវត្តន៍នូវច្បាប់ ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និង សន្ធិសញ្ញាអូតាវ៉ាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និង ការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល

៤.១២.តាមដានពិនិត្យ និងផ្តល់ការណែនាំក្នុងការប្រើប្រាស់ថវិកា សម្ភារៈបរិក្ខារ និងធនធានផ្សេងៗ ដែលផ្តល់ដល់អង្គការប្រតិបត្តិករជាតិ និងអន្តរជាតិទាំងអស់ ។ ធនធាននេះ អាចរួមទាំងធនធានឧបត្ថម្ភដោយរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ជាតិ-អន្តរជាតិ ក្រុមហ៊ុនឯកជន និង សប្បុរសជននានា ។

**មាត្រា ៥ :**

"អាជ្ញាធរ" មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និង មានអង្គភាព ឬ នាយកដ្ឋានមួយចំនួនទៀត តាមការចាំបាច់នៃការបំពេញការងារទូទៅរបស់ "អាជ្ញាធរ" ។

## ជំពូកទី ៤

## អគ្គលេខាធិការ

**មាត្រា ៦ :**

អគ្គលេខាធិការ មានភារកិច្ចចាំបាច់ដូចតទៅ :

៦.១. គ្រប់គ្រងចាត់ចែង និង ដឹកនាំការងារប្រចាំថ្ងៃរបស់ "អាជ្ញាធរ" និង សំរបសំរួលរាល់ការងារសកម្មភាពកំចាត់មីនរបស់អង្គការប្រតិបត្តិករទាំងអស់ និង សហគមន៍ម្ចាស់ជំនួយ ជំនួសមុខឱ្យ "អាជ្ញាធរ" ។ អគ្គលេខាធិការ មានអគ្គលេខាធិការរងពីររូបជាជំនួយការដែលត្រូវតែងតាំងដោយអនុក្រឹត្យ ។ អគ្គលេខាធិការត្រូវរាយការណ៍ជូនអនុប្រធាន "អាជ្ញាធរ" ។

៦.២. រៀបចំការប្រជុំឱ្យបានទៀងទាត់ជាមួយបណ្ដាអង្គការប្រតិបត្តិករ ដែលធ្វើប្រតិបត្តិការសកម្មភាពមីន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦.៣. រៀបចំអង្គប្រជុំអោយបានទៀងទាត់ជាមួយភ្នាក់ងារផ្ដល់ជំនួយ ដើម្បីធានានូវគោលនយោបាយសំរបសំរួល និង ពង្រឹងភាពជាដៃគូ ។

៦.៤. ចាត់ចែង និងចេញបញ្ជាចំណាយនានា តាមគំរោងថវិកាដែលបានអនុម័ត ហើយនិងគ្រប់គ្រងលើរាល់ចំណូល-ចំណាយប្រចាំឆ្នាំរបស់ "អាជ្ញាធរ" ។

## ជំពូកទី ៥

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៧ :**

៧.១. អគ្គលេខាធិការដ្ឋានត្រូវស្ថិតក្រោមការដឹកនាំគ្រប់គ្រងរបស់អគ្គលេខាធិការ ។ ដើម្បីធានាឱ្យមានប្រសិទ្ធិភាព និង សុក្រឹត្យភាពការងារខ្ពស់របស់ "អាជ្ញាធរ" អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានចំនួនប្រាំមួយ សំរាប់បំរើការងារតាមមុខងារដូចតទៅ :

៧.១.១. បទប្បញ្ញត្តិ និង នីតិកម្ម

៧.១.២. ផែនការ ត្រួតពិនិត្យ និង គ្រប់គ្រងទិន្នន័យ

៧.១.៣. កិច្ចសង្គ្រោះជនពិការ

៧.១.៤. សំរបសំរួល និង ទំនាក់ទំនងសាធារណៈ

៧.១.៥. រដ្ឋបាល-បុគ្គលិក និង ភស្តុភារ

៧.១.៦. ហិរញ្ញវត្ថុ

៧.២. អគ្គលេខាធិការដ្ឋាន ត្រូវប្រព្រឹត្តទៅតាមបទបញ្ជាផ្ទៃក្នុង ដែលអនុម័តដោយគណៈអធិបតី "អាជ្ញាធរ" ។

មាត្រា ៨ :

អគ្គលេខាធិការដ្ឋាន ត្រូវមានត្រាមួយដោយឡែករបស់ខ្លួន ។

មាត្រា ៩ :

នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប ព្រមទាំងសហការីមួយចំនួនជាជំនួយការ ។ ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ១០ :

១០.១. បុគ្គលិកដែលបំរើការឱ្យអគ្គលេខាធិការដ្ឋាន មានពីរប្រភេទ : មន្ត្រីរាជការផ្ទេរមកពីក្រសួង ឬ ស្ថាប័នរដ្ឋនានា និង បុគ្គលិកជាប់កិច្ចសន្យា ។ បុគ្គលិកទាំងពីរប្រភេទនេះ ត្រូវឆ្លងកាត់ការប្រលងជ្រើសរើសប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើសមត្ថភាព វិទ្យាកោសល្យ និង បទពិសោធន៍ការងារ ។

១០.២. ចំពោះបុគ្គលិកដែលជាមន្ត្រីរាជការ នៃក្រសួង ឬ ស្ថាប័នរដ្ឋនានាដែលមានបំណងចង់មកបំរើការនៅអគ្គលេខាធិការដ្ឋាន ត្រូវឆ្លងកាត់ការប្រលងប្រកួតសមត្ថភាព មុននឹងស្នើសុំផ្ទេរក្របខ័ណ្ឌ និង ភារកិច្ចរបស់ខ្លួន ។

១០.៣. បទបញ្ជាផ្ទៃក្នុងនៃការគ្រប់គ្រងការងារបុគ្គលិក ត្រូវស្ថិតនៅក្នុងលក្ខខ័ណ្ឌការងារដោយឡែក ដែលកំណត់ដោយសេចក្តីសំរេចរបស់គណៈអធិបតី "អាជ្ញាធរ" ។

## ជំពូកទី ៦

## នាយកដ្ឋានបទប្បញ្ញត្តិ និង នីតិកម្ម

**មាត្រា ១១ :**

នាយកដ្ឋានបទប្បញ្ញត្តិ និង នីតិកម្ម មានភារកិច្ចដូចតទៅ :

១១.១. រៀបចំ និង ពិនិត្យឯកសារកិច្ចព្រមព្រៀងសំរាប់ចុះហត្ថលេខារវាង "អាជ្ញាធរ" និង ម្ចាស់ជំនួយ

១១.២. រៀបចំនីតិវិធីនានា និង ដាក់ឱ្យដំណើរការ នូវការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណដល់គ្រប់អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ភ្នាក់ងារឯកជន ដែលអនុវត្តសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដំណើរការនេះ ត្រូវប្រព្រឹត្តិទៅប្រកបដោយត្រឹមត្រូវ និង មានតម្លាភាព

១១.៣. គ្រប់គ្រងរាល់ការប្រើប្រាស់ ដឹកជញ្ជូន បែងចែក និង ស្តុកទុកនូវគ្រាប់រំសេវ និងគ្រឿងផ្ទុះរបស់ប្រតិបត្តិករសកម្មភាពមីននានា

១១.៤. រៀបចំកិច្ចដំណើរការ ដើម្បីចេញបញ្ជាអោយកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្សរថក្រោះ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលរកឃើញដោយរាល់ប្រតិបត្តិករសកម្មភាពមីន ហើយដែលអាជ្ញាធរមានសមត្ថកិច្ចមិនកាន់កាប់ និង មិនប្រើប្រាស់

១១.៥. រៀបចំចេញផ្សាយនូវស្តង់ដាបច្ចេកទេស នីតិវិធី គោលការណ៍ បទប្បញ្ញត្តិនានា ដែលទាក់ទងនឹងសកម្មភាពមីន

១១.៦. រៀបចំ និង ប្រមូលផ្តុំឯកសារ និង អនុសាសន៍នានា សំរាប់ "អាជ្ញាធរ" ធ្វើការដកហូតនូវប័ណ្ណទទួលស្គាល់ពីអង្គការប្រតិបត្តិករជាតិ និងអន្តរជាតិ ដែលធ្វើសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា

១១.៧. ត្រួតពិនិត្យការអនុវត្តន៍ នូវច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់មីនគ្រប់ប្រភេទប្រឆាំងមនុស្សជាតិ និង សន្ធិសញ្ញាអូតាវ៉ាស្តីពីការហាមប្រាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល ។

## ជំពូកទី ៧

## នាយកដ្ឋានផែនការ ត្រួតពិនិត្យ និង គ្រប់គ្រងទិន្នន័យ

**មាត្រា ១២ :**

នាយកដ្ឋានផែនការ ត្រួតពិនិត្យ និង គ្រប់គ្រងទិន្នន័យមានភារកិច្ចដូចតទៅ :

១២.១. រៀបចំស្តង់ដាបច្ចេកទេស នីតិវិធី គោលការណ៍ ថវិកា និង បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងទៅនឹងការធ្វើផែនការសកម្មភាពមីន និង ការគ្រប់គ្រងពត៌មានបច្ចេកទេស

១២.២. រៀបចំផែនការជាតិសកម្មភាពមីន (រាយការណ៍ពាក់ព័ន្ធ និងជាបន្តបន្ទាប់តាមពេល) រួមមានៈ

១២.២.១. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ នៃសកម្មភាពមីន និង សកម្មភាពទ្រទ្រង់ផ្សេងៗ

១២.២.២. ពិនិត្យ និងជ្រើសរើសគំរោងស្នើ(ដោយផ្អែកលើផែនការសកម្មភាព) ដែលទាក់ទងទៅនឹងបញ្ហាមីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះដែលភាគីពាក់ព័ន្ធនានាជាក់ជូនមកដើម្បីផ្ញើទៅម្ចាស់ជំនួយ

១២.២.៣. រៀបចំយុទ្ធសាស្ត្រផ្សេងៗ និងឯកសារប្រហាក់ប្រហែលដទៃទៀតដែលទាក់ទងទៅនឹងសកម្មភាពជាតិក្នុងការគ្រប់គ្រងលើវិស័យសកម្មភាពមីន

១២.៣. ត្រួតពិនិត្យរាល់ប្រតិបត្តិការសកម្មភាពមីន ដើម្បីធានាឱ្យការអនុវត្តន៍ប្រព្រឹត្តិទៅតាមផែនការយុទ្ធសាស្ត្ររបស់ជាតិ និង តាមស្តង់ដាជាតិ និង អន្តរជាតិ ស្តីពីសកម្មភាពមីន

១២.៤. គ្រប់គ្រង និង រៀបចំមូលដ្ឋានទិន្នន័យប្រមូលផ្តុំនូវរាល់ឯកសារទាក់ទងនឹងសកម្មភាពមីន ដែលបានចុះបញ្ជី និង រក្សាទុក

១២.៥. សហការជាមួយភ្នាក់ងារបោសសំអាតមីនទាំងឡាយ ដើម្បីធានាដំណើរការប្រកបដោយគុណភាពនូវការផ្លាស់ប្តូរពត៌មានទាំងក្នុង និងក្រៅប្រទេស និង ត្រួតពិនិត្យទៅតាមផែនការជាតិស្តីពីសកម្មភាពមីន

១២.៦. ជួយក្នុងកិច្ចសំរបសំរួលជាមួយម្ចាស់ជំនួយ ភ្នាក់ងារអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ ប្រទេសនានា ស្ថាប័នរដ្ឋ និង អាជ្ញាធរពាក់ព័ន្ធ ភ្នាក់ងារឯកជន ដើម្បីរៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រ ធានាឱ្យមានភាពរីកចំរើនជឿនលឿនដល់គំរោងការណ៍ក្នុងប្រទេសកម្ពុជា ហើយដែលត្រូវបាន និង កំពុងអនុវត្តក្នុងបរិយាកាសប្រកបដោយសុវត្ថិភាពកំរិតខ្ពស់ ។

## ជំពូកទី ៨

## នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន

មាត្រា ១៣ :

នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន មានភារកិច្ចដូចតទៅ :

១៣.១. តាមដានការងារសង្គ្រោះជនរងគ្រោះដោយសារមីនជាមួយភ្នាក់ងារពាក់ព័ន្ធផ្សេងៗ មានក្រសួង

សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និង ស្ថាប័នជាតិ ក៏ដូចជាអន្តរជាតិនានា ដែលមានការពាក់ព័ន្ធ ។ ការគ្រប់គ្រង ការសំរបសំរួល និង ការឃ្លាំមើលលើកិច្ចសង្គ្រោះជនពិការដោយសារមីនភាគច្រើន គឺជាការទទួលខុសត្រូវរបស់អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ និង អង្គការពាក់ព័ន្ធនានា ។ អង្គការទាំងនោះ ត្រូវផ្តល់ជូន "អាជ្ញាធរ" នូវផែនការយុទ្ធសាស្ត្រនៃសកម្មភាពការងារ និងរបាយការណ៍រីកចំរើន ស្តីពីសកម្មភាពសង្គ្រោះជនពិការដោយសារមីន

១៣.២. ធ្វើការទំនាក់ទំនងជាមួយភ្នាក់ងារ និង អង្គការពាក់ព័ន្ធនានា ដើម្បីស្រង់យកពត៌មានស្តីពីស្ថិតិ និង អត្រាគ្រោះថ្នាក់ និង សេវាកម្មពាក់ព័ន្ធនានា

១៣.៣. ទទួលរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ពីអង្គការជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងកិច្ចសង្គ្រោះជនពិការដោយសារមីន

១៣.៤. ធ្វើសេចក្តីរាយការណ៍រីកចំរើនប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ស្តីពីសកម្មភាពសង្គ្រោះជនពិការដោយសារមីន ជូនអគ្គលេខាធិការ ។

## ជំពូកទី ៩

## នាយកដ្ឋានសំរបសំរួល និង ទំនាក់ទំនងសាធារណៈ

**មាត្រា ១៤ :**

នាយកដ្ឋានសំរបសំរួល និង ទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ :

១៤.១. រៀបចំតាក់តែងឯកសារពត៌មាន ការបោះពុម្ពផ្សាយ ជាពិសេសបោះពុម្ពផ្សាយសកម្មភាពរបស់ "អាជ្ញាធរ" និងរៀបចំប្រព័ន្ធទំនាក់ទំនងដែលទាក់ទងនឹងសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា

១៤.២. ធ្វើទំនាក់ទំនងជាមួយភ្នាក់ងារពត៌មានជាតិ និង អន្តរជាតិ

១៤.៣. សំរបសំរួលជាមួយអង្គការជាតិ-អន្តរជាតិ និង រៀបចំចាត់ចែងដំណើរទស្សនៈកិច្ចនានារបស់ភ្ញៀវជាតិ-អន្តរជាតិ

១៤.៤. រៀបចំរបាយការណ៍នានាដាក់ជូនម្ចាស់ជំនួយ

## ជំពូកទី ១០

## នាយកដ្ឋានរដ្ឋបាល-បុគ្គលិក និង ភស្តុភារ

**មាត្រា ១៥ :**

នាយកដ្ឋានរដ្ឋបាល-បុគ្គលិក និង ភស្តុភារ មានភារកិច្ចដូចតទៅ :

១៥.១. រៀបចំចាត់ចែងភស្តុភារ និង ការទិញសំភារៈ

១៥.២. រៀបចំតាក់តែង និង តាមដានការអនុវត្តន៏បទបញ្ជាផ្ទៃក្នុង និង បទប្បញ្ញត្តិផ្សេងៗ

១៥.៣. រៀបចំលិខិតបទដ្ឋាន ទំនាក់ទំនងជាមួយអង្គការជាតិ និង អន្តរជាតិ

១៥.៤. គ្រប់គ្រងរាល់លិខិតបទដ្ឋាន និង ឯកសារទិន្នន័យបុគ្គលិក

១៥.៥. តំកល់ ត្រួតពិនិត្យ និង ចុះបញ្ជីនូវរាល់ឯកសារចេញ-ចូល

១៥.៦. រៀបចំ និង ធ្វើការជ្រើសរើសបុគ្គលិក តាមលក្ខណៈវិនិច្ឆ័យ ប្រកបដោយតម្លាភាព និងអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាល

១៥.៧. សំរបសំរួល ទាក់ទងជាមួយអង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់លើការងារភស្តុភារ

## ជំពូកទី ១១

## នាយកដ្ឋានហិរញ្ញវត្ថុ

**មាត្រា ១៦ :**

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ :

១៦.១. ត្រួតពិនិត្យ និង ផ្តល់ការណែនាំ ក្នុងការប្រើប្រាស់ថវិកា និង សម្ភារៈបរិក្ខារ ដែលផ្តល់ដោយជំនួយរាជរដ្ឋាភិបាល និង សហគមន៍ជាតិ-អន្តរជាតិ ដល់អង្គការប្រតិបត្តិករសកម្មភាពមីននានា

១៦.២. គ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ និង គណនេយ្យ

១៦.៣. រៀបចំគំរោងថវិកា

១៦.៤. រៀបចំ និង ត្រួតពិនិត្យបទប្បញ្ញត្តិហិរញ្ញវត្ថុនៃអង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់

១៦.៥. អនុម័តលើការចំណាយសាច់ប្រាក់ ដោយមានការអនុញ្ញាតិពីអគ្គលេខាធិការ

១៦.៦. រៀបចំ និង បញ្ជាក់និយ័តភាពគណនេយ្យប្រចាំឆមាស និង ប្រចាំឆ្នាំ

១៦.៧. ធ្វើសេចក្តីរាយការណ៍ចំណូល-ចំណាយ និងស្ថានភាពហិរញ្ញវត្ថុរៀងរាល់ខែជូនអគ្គលេខាធិការ ។

## ជំពូកទី ១២
## យន្តការត្រួតពិនិត្យបច្ចេកទេស និង បទប្បញ្ញត្តិ

**មាត្រា ១៧ :**

អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ។

**មាត្រា ១៨ :**

រាល់បណ្តាអង្គការប្រតិបត្តិករ ដែលមានបំណងចង់ធ្វើប្រតិបត្តិការសកម្មភាពមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវសុំប័ណ្ណទទួលស្គាល់ និង អាជ្ញាប័ណ្ណ អនុញ្ញាតពី "អាជ្ញាធរ" ។ នីតិវិធីសំរាប់ផ្តល់ប័ណ្ណទទួលស្គាល់ និង អាជ្ញាប័ណ្ណ នឹងមានចែងលំអិតនៅក្នុងគោលនយោបាយដាច់ដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

**មាត្រា ១៩ :**

អគ្គលេខាធិការដ្ឋាន ត្រូវបង្កើតឱ្យមានក្រុមពិគ្រោះយោបល់បច្ចេកទេសសកម្មភាពមីនមួយ ។ ក្រុមនេះត្រូវមានតំណាងអ្នកឯកទេសមកពីអង្គការប្រតិបត្តិករជាតិ-អន្តរជាតិ និង ក្រសួងពាក់ព័ន្ធនានា ។

**មាត្រា ២០ :**

មន្ត្រីអគ្គលេខាធិការដ្ឋានត្រូវចុះឱ្យបានទៀងទាត់ ដើម្បីពិនិត្យមើលការអនុវត្តន៍នៃកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីធានានូវសុវត្ថិភាព និង ប្រសិទ្ធភាព ។ នីតិវិធីត្រួតពិនិត្យ និង វាយតំលៃ នឹងត្រូវចែងលំអិតក្នុងគោលនយោបាយដោយឡែកដែលចេញដោយ "អាជ្ញាធរ" និងមានគោលការណ៍ណែនាំដូចតទៅ :

២០.១. អគ្គលេខាធិការដ្ឋាន ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់អង្គភាពដែលត្រូវចុះទៅត្រួតពិនិត្យឱ្យបានយ៉ាងហោចណាស់មួយអាទិត្យមុនថ្ងៃចុះទៅដល់ការដ្ឋានឬកន្លែងដែលត្រូវទៅត្រួតពិនិត្យ

២០.២. មុនពេលចាប់ផ្តើមចេញដំណើរ ប្រធានក្រុមត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន ត្រូវសាកសួរអ្នកទទួលខុសត្រូវរបស់អង្គការប្រតិបត្តិករដែលត្រូវធ្វើការត្រួតពិនិត្យ ដើម្បីទាញការចាប់អារម្មណ៍លើបញ្ហាសំខាន់ៗ

២០.៣. ប្រធានក្រុមត្រួតពិនិត្យត្រូវរៀបចំរបាយការណ៍ដាក់ជូនអគ្គលេខាធិការដ្ឋាន ។ របាយការណ៍នេះត្រូវចំលងជូនទៅអង្គការប្រតិបត្តិករ ។ អគ្គលេខាធិការដ្ឋាន ត្រូវផ្ញើលិខិតជាផ្លូវការទៅអង្គការ

ប្រតិបត្តិករដែលត្រូវត្រួតពិនិត្យនោះជាលាយល័ក្ខអក្សរ ដោយបញ្ជាក់ពីខ្លឹមសារ អនុសាសន៍ តំរង់ទិស ដែលត្រូវធ្វើការកែលំអ និងបញ្ជាក់ពីថេរៈវេលាដែលត្រូវអនុវត្តអនុសាសន៍នេះផង

២០.៤. រាល់របាយការណ៍ត្រួតពិនិត្យ/វាយតំលៃ ដែលរៀបចំដោយ "អាជ្ញាធរ" ត្រូវរក្សាទុកជាការសំងាត់

២០.៥. បញ្ហាដែលត្រូវបានកត់សំគាល់ដោយប្រធានក្រុមត្រួតពិនិត្យ ត្រូវមានការគូសបញ្ជាក់បំភ្លឺ ពីអង្គការប្រតិបត្តិករ ។ បើបញ្ហានោះមានភាពធ្ងន់ធ្ងរ អគ្គលេខាធិការដ្ឋាន ត្រូវអញ្ជើញអង្គការប្រតិបត្តិករនោះ មកធ្វើការបង្ហាញនូវការកែតំរូវលើការគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការ ដោយគោរពយ៉ាងពេញលេញទៅតាមការតំរូវដូចមានចែងក្នុងរបាយការណ៍ ។

## ជំពូកទី ១៣
## យន្តការរៀបចំផែនការ ការត្រួតពិនិត្យ ការអនុវត្តន៍ និង ការគ្រប់គ្រងថវិកា

### មាត្រា ២១ :

២១.១. ការរៀបចំផែនការយុទ្ធសាស្ត្រដែលជាចក្ខុវិស័យរយៈពេលវែង នៃសកម្មភាពមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ជាភារៈកិច្ចរបស់ "អាជ្ញាធរ" ។ ដើម្បីធានាឱ្យខ្លឹមសារនៃផែនការជាយុទ្ធសាស្ត្រនេះគ្របដណ្តប់បានគ្រប់ជ្រុងគ្រប់ជ្រោយ "អាជ្ញាធរ" ត្រូវបង្កើតគណៈកម្មការពិគ្រោះមួយ ដែលមានសមាសភាពដូចតទៅ :

- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តំណាងក្រសួងការពារជាតិ
- តំណាងក្រសួងមហាផ្ទៃ
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តំណាងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ/បញ្ជាការដ្ឋានកងវិស្វកម្ម
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ
- តំណាងក្រសួងផែនការ
- តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន
- តំណាងក្រសួងធនធានទឹក និង ឧត្តុនិយម

- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តំណាងអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធនឹងសកម្មភាពមីន
- តំណាងម្ចាស់ជំនួយ

២១.២. តំរូវការ និងនីតិវិធីចាំបាច់នានា ដែលទាក់ទងនឹងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្ររបស់ជាតិ នឹងត្រូវចែងលំអិតក្នុងគោលនយោបាយដោយឡែកដែលចេញដោយ "អាជ្ញាធរ" ។

មាត្រា ២២ :

ផែនការជាយុទ្ធសាស្ត្រនេះ បន្ទាប់ពីបានទទួលការអនុម័តពីនាយករដ្ឋមន្ត្រី នឹងត្រូវចូលជាធរមានក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីថ្ងៃចុះហត្ថលេខា ។ ផែនការជាយុទ្ធសាស្ត្រនេះគឺជាផែនការរបស់រាជរដ្ឋាភិបាល ដែលរាល់បណ្តាអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ត្រូវយកជាមូលដ្ឋានគោលសំរាប់រៀបចំ ឬ សំរបសំរួលផែនការរបស់ខ្លួន ។

មាត្រា ២៣ :

អង្គការប្រតិបត្តិករជាតិ និងអន្តរជាតិសកម្មភាពមីនទាំងអស់ ត្រូវរៀបចំធ្វើផែនការរយៈពេលខ្លី ឬ រយៈពេលវែងរបស់ខ្លួន មកអគ្គលេខាធិការដ្ឋាន ដើម្បីបញ្ចូលជាមួយផែនការមេរបស់ជាតិ ។

មាត្រា ២៤ :

ប្រតិបត្តិករទាំងអស់ ចាំបាច់ត្រូវអនុវត្តសកម្មភាពទៅតាមផែនការដែលបានអនុម័តហើយ ។ អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ត្រូវមានភារកិច្ចត្រួតពិនិត្យឱ្យបានទៀងទាត់ដើម្បីធានាការអនុវត្តន៍ឱ្យចំទិសដៅ ពិសេសស្របទៅនឹងផែនការជាតិ ។

មាត្រា ២៥ :

អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ជាមជ្ឈមណ្ឌលជាតិទទួលបន្ទុកគ្រប់គ្រងទិន្នន័យនៃសកម្មភាពមីន នៅព្រះរាជាណាចក្រកម្ពុជា ។ រាល់បណ្តាអង្គការប្រតិបត្តិករទាំងអស់ទាំងសកម្មភាពមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវធ្វើសេចក្តីរាយការណ៍ឱ្យបានទៀងទាត់ ប្រចាំត្រីមាស ឆមាស និង ឆ្នាំ មកអគ្គលេខាធិការដ្ឋាន ។ ខ្លឹមសារនៃសេចក្តីរាយការណ៍ ត្រូវមានយ៉ាងហោចសកម្មភាព លទ្ធផលនៃកម្មវិធីនីមួយៗ

របាយការណ៍ហិរញ្ញវត្ថុ និង ពត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ច-សង្គមផង ។ តំរូវការចាំបាច់នានាសំរាប់រាយការណ៍ និង ការធ្វើរបាយការណ៍ នឹងមានចែងលំអិតក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

មាត្រា ២៦ :

ក្រោយពីបានទទួលការសំរេចជាគោលការណ៍ពីគណៈអចិន្ត្រៃយ៍ "អាជ្ញាធរ" អគ្គលេខាធិការមានសិទ្ធិចុះកិច្ចសន្យាបន្តទៅក្រុមហ៊ុន ឬភ្នាក់ងារដែលមានសមត្ថភាពដទៃទៀត ដើម្បីទទួលភារៈកិច្ចផ្ទាល់របស់ខ្លួន ។ នីតិវិធីនៃការចុះកិច្ចសន្យាបន្ត ត្រូវអនុវត្តទៅតាមនីតិវិធី និង គោលការណ៍លទ្ធកម្មរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ១៤
## យន្តការគ្រប់គ្រងដីធ្លីបោសសំអាតមីនហើយ

មាត្រា ២៧ :

ដើម្បីធានានូវការប្រើប្រាស់ដីធ្លីដែលបោសសំអាតមីនហើយ ប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពកំរិតខ្ពស់ អង្គការប្រតិបត្តិករទាំងអស់ ត្រូវអនុវត្តទៅតាមបែបបទនៃការរៀបចំផែនការ និង ការគ្រប់គ្រងសកម្មភាពមីន ដែលនឹងមានចែងនៅក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ក៏ដូចជាចំពោះនីតិវិធីនានាសំរាប់គ្រប់គ្រងដីធ្លី ដែលចេញដោយអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ។ ផែនការ និង អនុសាសន៍ លំដាប់ខេត្ត ស្រុក ឃុំ ភូមិ ដែលបានឯកភាពនិងលើកឡើង ត្រូវផ្ញើមកអគ្គលេខាធិការដ្ឋាន"អាជ្ញាធរ" ដោយប្រធានគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការលើកគំរោងលំដាប់ជាតិ និង សំរាប់ធ្វើការត្រួតពិនិត្យ និង តាមដាន ។

មាត្រា ២៨ :

តំរូវការ និង ដំណើរការចាំបាច់នានា ដែលទាក់ទងទៅនឹងការលើកគំរោងសំរាប់កិច្ចប្រតិបត្តិការបោសសំអាតមីន និង ការគ្រប់គ្រងដីធ្លី នឹងមានចែងលំអិតក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

## ជំពូកទី ១៥
## យន្តការគ្រប់គ្រងសេវាកម្ម កិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន

**មាត្រា ២៩ :**

រាល់ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យសេវាកម្ម និង ការសំរបសំរួលកិច្ចសង្គ្រោះជនពិការដោយសារមីន ជាភារកិច្ចរបស់ "អាជ្ញាធរ" ។ ដោយយន្តការផ្នែកនេះមានដំណើរការហើយ "អាជ្ញាធរ" ប្រគល់ភារកិច្ចសំរបសំរួលនេះទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា និង អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ តាមរយៈការទទួលស្គាល់នូវប្រកាសលេខ ៣០៨ ក.ស.ប.យ. ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៩ ។ "អាជ្ញាធរ" អាចផ្តល់អនុសាសន៍ចំពោះរាល់សកម្មភាពសង្គ្រោះជនពិការដោយសារមីន និង ក្នុងករណីចាំបាច់ "អាជ្ញាធរ" អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យទៅចូលរួមក្នុងប្រតិបត្តិការសង្គ្រោះនោះជាមួយអង្គការ និង ភ្នាក់ងារទាំងឡាយដែលទទួលបន្ទុកការងារនេះ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើរបាយការណ៍រីកចំរើនប្រចាំត្រីមាស ឆមាស និង ឆ្នាំ មក "អាជ្ញាធរ" អោយបានទៀងទាត់ ។

## ជំពូក ១៦
## សិទ្ធិប្រធានចូលរួមប្រជុំអន្តរជាតិ

**មាត្រា ៣០ :**

ការអនុញ្ញាតិតំណាងរាជរដ្ឋាភិបាលកម្ពុជាឱ្យចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីសកម្មភាពមីន ជាសិទ្ធិរបស់នាយករដ្ឋមន្ត្រី ។ រាល់ការស្នើសុំរបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំនានា ដែលទាក់ទងទៅនឹងសកម្មភាពមីន ចាំបាច់ត្រូវធ្វើលិខិតសុំការអនុញ្ញាតិមក "អាជ្ញាធរ" ។

**មាត្រា ៣១ :**

អគ្គលេខាធិការដ្ឋាននៃ "អាជ្ញាធរ" ត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់តាំងប្រតិភូទៅចូលរួមប្រជុំនេះ ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការ "អាជ្ញាធរ" អាចស្នើសុំក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចាត់តាំងមន្ត្រីការទូតទៅចូលរួមបាន ។

**មាត្រា ៣២ :**

មន្ត្រីដែលបានអនុញ្ញាតឱ្យទៅចូលរួមសម័យប្រជុំ ត្រូវធ្វើសេចក្តីរាយការណ៍តាមរយៈរដ្ឋមន្ត្រី ឬ តំណាង

ស្ថាប័នពាក់ព័ន្ធផ្ញើមក "អាជ្ញាធរ" ។ របាយការណ៍នេះ ត្រូវសរុបនូវខ្លឹមសារសង្ខេបរបស់កិច្ចប្រជុំ ដោយភ្ជាប់ឯកសារនានា ហើយក្នុងករណីចាំបាច់ត្រូវលើកជាអនុសាសន៍ ឬ សំណើផ្សេង១ផង ។

## ជំពូកទី ១៧
## ពិធីការលើកិច្ចចុះហត្ថលេខាលើកិច្ចព្រមព្រៀង

**មាត្រា ៣៣ :**

"អាជ្ញាធរ" មានតួនាទីតំណាងឱ្យរាជរដ្ឋាភិបាល លើរាល់កិច្ចសន្យា ឬកិច្ចព្រមព្រៀងនានាស្តីពីសកម្មភាពមីន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤ :**

៣៤.១. កម្មវិធី និង គំរោងនានា ដែលទាក់ទងនឹងកិច្ចប្រតិបត្តិការសកម្មភាពមីន ចាំបាច់ត្រូវមានអនុស្សរណៈ រវាង "អាជ្ញាធរ" និង ភ្នាក់ងារផ្តល់ជំនួយ ។

៣៤.២. កិច្ចព្រមព្រៀងផ្តល់ថវិការវាងភ្នាក់ងារផ្តល់ជំនួយ និង អង្គការប្រតិបត្តិករ អាចចុះហត្ថលេខាដោយឡែកបាន ហើយមន្ត្រីនៃ "អាជ្ញាធរ" អាចធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខានេះ ។ ឯកសារដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងផ្តល់ថវិកាទាំងនេះ ត្រូវផ្ញើមកតំកល់ទុកនៅអគ្គលេខាធិការដ្ឋាននៃ "អាជ្ញាធរ" ។

## ជំពូកទី ១៨
## ការអនុវត្តន៍សន្ធិសញ្ញាអូតាវ៉ា

**មាត្រា ៣៥ :**

"អាជ្ញាធរ" ជាតំណាងរបស់រាជរដ្ឋាភិបាល ហើយត្រូវសហការជាមួយស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតូបករណ៍អន្តរជាតិទាំងឡាយក្នុងការបំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងបញ្ហាមីនប្រឆាំងមនុស្សគ្រប់ប្រភេទ ។

**មាត្រា ៣៦ :**

"អាជ្ញាធរ" ត្រូវកោះអញ្ជើញក្រសួង ស្ថាប័ន អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ដែលធ្វើប្រតិបត្តិការសកម្មភាពមីន មករួមប្រជុំដើម្បីប្រមូលទិន្នន័យ លទ្ធផល ឬបញ្ហាផ្សេង១ទៀត ដើម្បីរួមចំណែកក្នុងការរៀបចំរបាយការណ៍ជាតិតាមលំនាំបែបបទជាលក្ខណៈអន្តរជាតិ ស្តីពីសកម្មភាពមីន ។ កិច្ចប្រជុំនេះ ត្រូវ

រៀបចំឡើងយ៉ាងហោចណាស់ឱ្យបានមួយខែមុនថ្ងៃកំណត់ ដែលត្រូវផ្ញើសេចក្តីរាយការណ៍ទៅអង្គការសហប្រជាជាតិ ។

## ជំពូកទី ២០
## ការអនុវត្តន៍ច្បាប់ ស្តីពីការហាមប្រាមការប្រើប្រាស់មីន ប្រឆាំងមនុស្សគ្រប់ប្រភេទ

**មាត្រា ៣៧ :**

ការអនុវត្តន៍ច្បាប់ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ២១
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨ :**

"អាជ្ញាធរ" តំរូវឱ្យអង្គការប្រតិបត្តិករសកម្មភាពមីនជាតិ និងអន្តរជាតិ ផ្តល់នូវរបាយការណ៍ស្តីពីអចលនទ្រព្យរបស់ខ្លួន ។ "អាជ្ញាធរ" ជាអ្នកទទួលពេញច្បាប់ នូវអចលនទ្រព្យទាំងឡាយដែលជាផ្នែកនៃកម្មវិធីសំរាប់សកម្មភាពមីន ហើយដែលម្ចាស់ជំនួយផ្ទេរជូនរាជរដ្ឋាភិបាល ។ អង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់ ត្រូវធ្វើលិខិតបញ្ជាក់ជាលាយល័ក្ខអក្សរផ្ញើមកអគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" នូវអចលនទ្រព្យដែលម្ចាស់ជំនួយផ្ទេរជូនរាជរដ្ឋាភិបាល ក្នុងរយះពេលមួយសប្តាហ៍មុនថ្ងៃទទួលជាក់ស្តែង ។ "អាជ្ញាធរ" នឹងធ្វើការត្រួតពិនិត្យ ក្នុងករណីចាំបាច់ជាក់ស្តែងត្រូវចាត់ចែងទុកដាក់នូវអចលនទ្រព្យទាំងនោះទៅតាមច្បាប់ និង បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៩ :**

"អាជ្ញាធរ" មានភារកិច្ចទទួលបន្ទុកផ្តួចផ្តើមកិច្ចអភិវឌ្ឍន៍បច្ចេកទេសថ្មីៗដែលសមស្រប ដើម្បីលើកកំពស់ និង ជំរុញសកម្មភាពបោសសំអាតមីនឱ្យមានប្រសិទ្ធិភាពកាន់តែខ្ពស់ឡើង រួមទាំងការស្រាវជ្រាវការពិសោធន៍ ការសាកល្បងគ្រឿងយន្ត និងបច្ចេកទេសថ្មីៗក្នុងព្រះរាជាណាចក្រកម្ពុជា ។ អង្គការដែលមានបំណងអនុវត្តការស្រាវជ្រាវ ការពិសោធន៍ និង ការសាកល្បងនេះ ត្រូវស្នើសុំជាលាយល័ក្ខអក្សរមកអគ្គលេខាធិការ "អាជ្ញាធរ" ។ របាយការណ៍ស្តីពីលទ្ធផលចុងក្រោយត្រូវដាក់ជូនមក "អាជ្ញាធរ" ។

មាត្រា ៤០ :

"អាជ្ញាធរ" នឹងជំរុញឱ្យមានចលនាផ្លាស់ប្តូរគ្នាទៅវិញទៅមកជាមួយនឹងបណ្តាប្រទេសដែលមានបញ្ហាមីន ដើម្បីលើកកំពស់ការហ្វឹកហ្វឺន ការអប់រំ និង សមត្ថភាពបច្ចេកទេសក្នុងប្រទេសកម្ពុជា ជាមួយបណ្តាប្រទេសដែលមានបញ្ហាមីនទាំងនោះ ។

## ជំពូកទី ២១

## អវសានប្បញ្ញត្តិ

មាត្រា ៤១ :

ក្នុងករណីមានភារកិច្ចដែលទាក់ទងសកម្មភាពមីន មានពាក់ព័ន្ធលើសមត្ថកិច្ចរបស់ស្ថាប័នដទៃ នាយករដ្ឋមន្ត្រីជាអ្នកសំរេចរៀបចំបែងចែកភារកិច្ចរវាង "អាជ្ញាធរ" និង ស្ថាប័នទាំងនោះ ។

មាត្រា ៤២ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤៣ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៣
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ